# ទំនៀមខ្លះក្រោយចូលឆ្នាំថ្មី

បន្ទាប់ពីចូលឆ្នាំថ្មីរួច គេសង្កេតឃើញមានពិធីបុណ្យខ្លះបន្តប្រារព្ធឡើងនៅតាមស្រុកភូមិនានាទៅតាមទំនៀម។ ពិធីជាទំនៀមទាំងនោះ គេតែងធ្វើក្នុងចន្លោះពេលមួយបន្ទាប់ពីចូលឆ្នាំហើយមួយរយៈខ្លី ពោលគឺធ្វើមុនដំណាច់ខែចេត្រឆ្លងចូលដល់ខែពិសាខ ហើយតំបន់ខ្លះហៅជាទូទៅថាឆ្លងចូលឆ្នាំ ឬខ្លះហៅថាឆ្លងចេត្រ ឬផ្ដាច់ចេត្រជាដើម។[1] ក្នុងខ្លឹមសារខាងក្រោម ខ្ញុំសាកល្បងរៀបរាប់យ៉ាងសង្ខេបជូនជ្រាបអំពីទំនៀមឆ្លងចូលឆ្នាំជាទូទៅ ទំនៀមសម្ដែងល្ខោនខោលក្រោយចូលឆ្នាំនៅវត្តស្វាយអណ្ដែត ទំនៀមទាញព្រ័ត្រថ្វាយអ្នកតាដើមសំរោងនៅស្រុកកោះធំ និងជាពិសេសទំនៀមឆ្លងចេត្រនៅភូមិនគរក្រៅ និងនៅកំពង់ក្ដី (ស្រុកជីក្រែង) ខេត្តសៀមរាប។

ជាការពិតបន្ទាប់ពីការប្រារព្ធពិធីចូលឆ្នាំចប់សព្វគ្រប់ទាំងបីថ្ងៃ តាមប្រពៃណីគេតែងធ្វើពិធីសំខាន់មួយទៀតគឺ "ឆ្លងចូលឆ្នាំ" ឬអ្នកខ្លះហៅថា "ស្រង់ព្រះ"។ ជាទូទៅពិធីនេះតែងប្រារព្ធធ្វើនៅក្នុងវត្ត ហើយវត្តខ្លះតែងរៀបចំធ្វើក្នុងថ្ងៃឡើងស័កតែម្ដង។ កិច្ចសំខាន់ៗក្នុងពេលនោះ គេមើលឃើញមានពីរគឺ ផ្សឹកភ្នំខ្សាច់ និងស្រង់ព្រះ។ ការផ្សឹកភ្នំខ្សាច់ គឺជាកិច្ចចាំបាច់ដែលគេជឿថាត្រូវតែធ្វើ ដ្បិតក្នុងថ្ងៃចូលឆ្នាំពុទ្ធបរិស័ទជិតឆ្ងាយបានធ្វើកិច្ចពូនភ្នំខ្សាច់ និងបំបួសភ្នំខ្សាច់ក្នុងជំនឿផ្ដាច់កម្មពៀរ។[2] ដូច្នេះក្នុងថ្ងៃឆ្លងចូលឆ្នាំ គេត្រូវធ្វើកិច្ចផ្សឹកភ្នំខ្សាច់នោះវិញ ដ្បិតកាលដែលបំបួសភ្នំខ្សាច់គេយល់ថា ពំនូកខ្សាច់នោះគឺទុកដូចជា "វាលុកចេតិយ"។[3] ចំពោះពិធីស្រង់ព្រះ គឺពុំទាន់ឃើញមានសេចក្ដីពន្យល់ច្បាស់លាស់ក្នុងឯកសារណាឡើយ តែពុទ្ធសាសនិកទូទៅជឿថាពិធីស្រង់ព្រះជាការលាងជម្រះនូវបាបកម្មទាំងឡាយដែលប្រព្រឹត្តិឡើងកាលពីឆ្នាំចាស់ ដើម្បីទទួលយកមកវិញនូវពរជ័យសិរីសួស្ដីក្នុងឆ្នាំថ្មី ជាពិសេសជាការសុំសេចក្ដីសុខ សេចក្ដីចម្រើនត្រជាក់ត្រជុំក្នុងក្រុមគ្រួសារ។ ការរៀបចំកិច្ចស្រង់ព្រះនេះសោត គេច្រើនអប់ទឹកដោយផ្កានិងគ្រឿងក្រអូបផ្សេងៗ រួចហើយកាន់សំដៅយកទៅវត្ត។ ជាទូទៅព្រះពុទ្ធបដិមាដែលគេ

---

[1] ខ្ញុំធ្លាប់លឺអ្នកភូមិខ្លះនៅភូមិបង្កោង ឃុំអំពិល ស្រុកប្រាសាទបាគងហៅ "ឆ្លងកន្ទុយចេត្រ" ផង។

[2] លី សុវីរ ១៩៩៤: ១៥។ ប៉ុន្តែអ្នកស្រាវជ្រាវខ្លះយល់ថា ភ្នំខ្សាច់ជាតំណាងឱ្យចក្រវាល ឬលោធាតុ។

[3] ឧកញ៉ាទេពពិទូរ ក្រសេម ១៩៦៩: ៥៣-៥៤

អត្ថបទដោយ៖ ហៀន សុវណ្ណមរកត

តែងរៀបចំកិច្ចស្រង់ទឹកនោះ ច្រើនជាព្រះបដិមាក្នុងព្រះវិហារ ឬព្រះបដិមាតម្កល់លើនៅសាលាធម្មសភា ឬជាពិសេសគឺព្រះពុទ្ធបដិមាដែលពុទ្ធបរិស័ទមានជំនឿថាមានបារមីខ្លាំងពូកែជាដើម។ មុននឹងធ្វើកិច្ចស្រោចស្រពស្រង់ព្រះ លោកអាចារ្យ ឬព្រះថេរអង្គណាមួយតែងដឹកនាំធ្វើកិច្ចវន្ទាខមាទោសសិន។ បន្ទាប់មកព្រះថេរជាធំក្នុងជំនុំសង្ឃនោះនិមន្តស្រង់ព្រះ រួចហើយព្រះសង្ឃអង្គផ្សេងបន្តបន្ទាប់ ទើបពុទ្ធបរិស័ទស្រង់ជាក្រោយ (រូបលេខ១-២)។



រូបលេខ១ សម្តេចព្រះអគ្គមហាសង្ឃរាជាធិបតី កិត្តិឧទ្ទេសបណ្ឌិត ទេព វង្ស សម្តេចព្រះសង្ឃរាជនៃព្រះរាជាណាចក្រកម្ពុជា និងជាព្រះចៅអធិការវត្តឧណ្ណាលោម និមន្តស្រង់ព្រះ
(រូបថត៖ វត្តឧណ្ណាលោម)



រូបលេខ២ ព្រះសង្ឃគង់នៅវត្តគល់ទទឹង និមន្តស្រង់ព្រះក្នុងថ្ងៃឆ្លងចូលឆ្នាំ
(រូបថត៖ វត្តគល់ទទឹង, ឆ្នាំ២០២១)

ចំពោះទំនៀមសម្តែងល្ខោនខោលក្រោយថ្ងៃចូលឆ្នាំ ប្រចាំនៅវត្តស្វាយអណ្តែតស្ថិតក្នុងស្រុកល្វាឯម ខេត្តកណ្តាល គឺជាទំនៀមរបស់អ្នកស្រុកតែងប្រារព្ធនៅថ្ងៃសៅរ៍ នៃសប្តាហ៍ទី១បន្ទាប់ពីចូលឆ្នាំថ្មីរួច។ ការសម្តែងនេះ គឺជាកង្វល់ធំរបស់អ្នកស្រុកដែលត្រូវរៀបចំធ្វើក្នុងបរិវេណវត្ត ក្នុងន័យជា "ពិធី" (ពុំមែនជាសិល្បៈមើលលេងកម្សាន្ត) មានការចូលរូប និងបន់ស្រន់ ពោលគឺសម្តែងជាតង្វាយដល់ "អស់លោក" (អ្នកតា) និងបារមីប្រចាំវត្តដើម្បីបួងសួងសុំទឹកភ្លៀង។ ការសម្តែងនោះសោត គឺជាធម្មតាមានរយៈពេលបីថ្ងៃ។ ថ្ងៃទី១ ឬហៅថាថ្ងៃហោមរោង គេធ្វើកិច្ច "យាងទសមុខ" មកតម្កល់ក្នុងរោងពិធី។ បន្ទាប់មកគេធ្វើកិច្ចសំពះគ្រូ និងរាំថ្វាយបារមីក្នុងព្រះវិហារ។ ក្នុងថ្ងៃទី២ គេសម្តែងសាច់រឿងផ្សេងៗ

អត្ថបទដោយ៖ ហៀន សុវណ្ណមរកត

តាមការកំណត់របស់អ្នកដឹកនាំ តែនៅយប់ចុងក្រោយគេត្រូវលើកយកអន្ទើ "កុម្ភកាណ៌ទប់ទឹក" មកសម្ដែង ដោយជឿថាការសម្ដែងអន្ទើនេះនឹងនាំឱ្យស្រុកភូមិមានទឹកគ្រប់គ្រាន់សម្រាប់ប្រកបរបរកសិកម្ម ព្រមទាំងបានសុខសប្បាយ (រូបលេខ៣-៤)។[៨]




រូបលេខ៣-៤ ការសម្ដែងល្ខោនខោលជាទំនៀមក្រោយថ្ងៃចូលឆ្នាំនៅវត្តស្វាយអណ្ដែត

រីឯទំនៀមទាញព្រ័ត្រក្រោយថ្ងៃចូលឆ្នាំនៅក្នុងឃុំកំពង់កុង ស្រុកកោះធំ ខេត្តកណ្ដាល គឺជាពិធីយ៉ាងសំខាន់របស់អ្នកស្រុកដែលប្រារព្ធថ្វាយអ្នកតាប្រចាំភូមិ (អ្នកតាដើមសំរោង)បន្ទាប់ពីចូលឆ្នាំរួចពីរឬបីថ្ងៃ។ អ្វីដែលគួរឱ្យពិចារណាក្នុងពិធីនេះ គឺការយកព្រ័ត្រដែលវេញពីផ្ដៅមកទាញផ្ដាច់មុខខ្ទមអ្នកតា ដោយមានព្រះសង្ឃប្រោះព្រំផង (រូបលេខ៥-៦)។ សូមកុំភ្លេចថាក្នុងសៀវភៅមហាសង្ក្រាន្តបុរាណៗលោកតែងហៅល្បែងទាញព្រ័ត្រជាល្បែងនក្ខត្តឫក្ស ពោលគឺពុំមែនជាល្បែងលេងល្បងកម្លាំងគ្នាយកចាញ់ឈ្នះក្នុងន័យជាកីឡាឡើយ។ រីឯការទាញព្រ័ត្រផ្ដាច់មុខខ្ទមអ្នកតានេះ គេយល់ថាជានិមិត្តរូបនៃការដាច់ឆ្នាំចាស់ចូលឆ្នាំថ្មី ពោលគឺការបញ្ចប់វដ្តកសិកម្មចាស់ផ្ដើមចូលវដ្តកសិកម្មថ្មី។[៩]

---

[៨] សូមអាន "ទំនៀមសម្ដែងល្ខោនខោលនៅវត្តស្វាយអណ្ដែតក្រោយថ្ងៃចូលឆ្នាំ" ដោយ ហៀន សុវណ្ណមរកត ផ្សាយលើតំណ https://ams.com.kh/khmercivilization/detail/20982

[៩] សូមអាន "ទំនៀមទាញព្រ័ត្រថ្វាយអ្នកតាដើមសំរោង" ដោយ ហៀន សុវណ្ណមរកត ផ្សាយលើតំណ https://ams.com.kh/khmercivilization/detail/19452 (ថ្ងៃទី៨ ខែមីនា ឆ្នាំ ២០២២) និង "ព្រ័ត្រផ្ដៅ" ដោយ ស៊ីយ៉ុន សុភារិទ្ធ, ជី វដ្ឋា, សាន ផល្វា, ស៊ុន ចាន់ដឹប, រិន

អត្ថបទដោយ៖ ហៀន សុវណ្ណមរកត



រូបលេខ៥-៦ ទំនៀមទាញព្រ័ត្រថ្វាយអ្នកតាក្រោយថ្ងៃចូលឆ្នាំនៅកំពង់កុង

ដោយឡែក ទំនៀមឆ្លងចេត្រ ឬផ្តាច់ចេត្រនៅក្នុងខេត្តសៀមរាប គឺជាទំនៀមដែលគេសម្គាល់ឃើញប្រារព្ធជាប់ពាក់ព័ន្ធនឹងអ្នកតាដែរ។ អ្នកស្រាវជ្រាវពន្យល់ថា "ឆ្លងចេត្រ" នៅទីនេះគ្រាន់តែមានន័យថា ឆ្លងផុតពីខែចេត្រចូលទៅខែពិសាខ ដែលជាខែចាប់ផ្តើមធ្លាក់ភ្លៀង ពោលគឺខែដែលគេចាប់ផ្តើមដាស់ដីភ្ជួររាស់ជាដើម។[៦] យ៉ាងណាក្តី អ្នកភូមិខ្លះអាចធ្វើពិធីឆ្លងចេត្រ រួចហើយស្រង់ព្រះពុទ្ធរូប ភ្ជាប់នឹងបុណ្យផ្សេងទៀតដែរដូចជាបុណ្យផ្កាប្រាក់ជាដើម។ ប៉ុន្តែជាទំនៀម បន្ទាប់ពីចប់ចូលឆ្នាំប្រហែលកន្លះខែ ភូមិភាគច្រើនស្ថិតនៅជុំវិញតំបន់អង្គរតែងធ្វើបុណ្យឆ្លងចេត្រនៅសាលាបុណ្យ ឬសាលាឆទានក្នុងភូមិនិងនិមន្តព្រះសង្ឃឆាន់ក្នុងថ្ងៃបញ្ចប់។ ក្នុងថ្ងៃបញ្ចប់ ឬថ្ងៃឆ្លងនោះ អ្នកភូមិរៀបចំទឹកអប់លាយរមៀត និងផ្កាភ្ញីសម្រាប់ស្រង់ព្រះ។ ឧទាហរណ៍មួយក្នុងរូបខាងក្រោមនេះ គឺជាពិធីឆ្លងចេត្រនៅភូមិនគរក្រៅ ដែលគេប្រារព្ធនៅសាលាឆទានក្នុងភូមិ (ឆ្នាំ២០១៤)។ ក្នុងពិធីនោះ នៅរសៀលថ្ងៃសូត្រមន្ត គេមានពូនភ្នំខ្សាច់ជាធម្មតាដូចថ្ងៃចូលឆ្នាំនៅវត្តដែរ។ លុះព្រឹកឡើងថ្ងៃឆ្លង គេធ្វើកិច្ចផ្សឹកភ្នំខ្សាច់ និមន្តព្រះសង្ឃឆាន់ រួចទើបធ្វើកិច្ចស្រង់ព្រះ និងស្រង់ទឹកជូនចាស់ទុំក្នុងភូមិ (រូបលេខ៧-៩)។ ផុតពីនោះ អ្នកភូមិនាំគ្នាដង្ហែផ្កាប្រាក់ទៅ

ឡៃជួ ផ្សាយលើតំណ http://www.yosothor.org/publications/khmer-renaissance/chapterfive/prot-pdav.html

៦ អាំង ជូលាន ២០១០-២០១១: ៣២-៣៥

អត្ថបទដោយ៖ ហឿន សុវណ្ណមរកត

ប្រគេនព្រះសង្ឃ និងធ្វើកិច្ចស្រង់ព្រះនៅវត្តទេពប្រណម្យ ស្ថិតក្នុងបរិវេណប្រាសាទអង្គរធំ (រូបលេខ១០-១១)។



រូបលេខ៧-៩ កិច្ចស្រង់ព្រះ និងស្រង់ទឹកចាស់ទុំក្នុងភូមិក្នុងពិធីឆ្លងចេត្រនៅភូមិនគរក្រៅ



រូបលេខ១០-១១ កិច្ចស្រង់ព្រះនៅវត្តទេពប្រណម្យក្នុងបរិវេណប្រាសាទអង្គរធំ

អរិយធម៌ខ្មែរ KHMER CIVILIZATION

ចំណែកឯឧទាហរណ៍មួយទៀត គឺទំនៀមទាញព្រ័ត្រផ្តាច់ចេត្រ (ឬឆ្លងចេត្រ) នៅស្ពានកំពង់ក្តី ស្ថិតក្នុងស្រុកជីក្រែង ខេត្តសៀមរាប។ ក្នុងទំនៀមនេះ គេឃើញមានកិច្ចពីរគឺសែនព្រេនថ្វាយភ្លេងនៅខ្ទមអ្នកតា "តាគង់" និងទាញព្រ័ត្រលើស្ពានកំពង់ក្តី ដែលជាស្ពានបុរាណ (ស.វ.ទី១២)។ ចំពោះកិច្ចថ្វាយភ្លេងនៅទួលអ្នកតា គឺដើម្បីបួងសួងសុំសេចក្តីសុខសុំឱ្យមានភ្លៀងធ្លាក់ល្អ។ បន្ទាប់មកគេនាំគ្នាកាន់ចប រនាស់ (រនាស់ដៃ) ធ្វើជាកាប់រាស់ដីក្បែរខ្ទមអ្នកតា ដោយអ្នកខ្លះដើរតាមក្រោយព្រាចគ្រាប់ពូជផង (រូបលេខ១២)។ កិច្ចចុងក្រោយ គេនាំគ្នាទាញព្រ័ត្របីដងនៅមុខខ្ទមអ្នកតា ទើបនាំគ្នាទៅធ្វើកិច្ចនៅលើស្ពាន។ កិច្ចដំបូងនៅទីនេះ គេនាំគ្នាសូត្រនមស្ការមុខក្បាលនាគបង្កាន់ដៃស្ពាន។ បន្ទាប់មកទើបគេសែនព្រេនថ្វាយភ្លេងបីបទ។ ចុងក្រោយ អ្នកស្រុកនាំគ្នាទាញព្រ័ត្រលើស្ពាននេះម្តងទៀត

អត្ថបទដោយ៖ ហៀន សុវណ្ណមរកត

ជាកិច្ចបញ្ចប់ (រូបលេខ១៣)។ សូមបញ្ជាក់ថា ពិធីឆ្លងចេត្រនៅទីនេះពុំឃើញមានកិច្ចពាក់ព័ន្ធនឹងព្រះសង្ឃដូចបណ្តាភូមិផ្សេងឡើយ។





*រូបលេខ១២-១៣ កិច្ចមុខខ្មមអ្នកតា និងនៅលើស្ពានក្នុងពិធីឆ្លងចេត្រនៅកំពង់ក្តី*

សរុបសេចក្តីមក បើមិននិយាយពីពិធីស្រង់ព្រះឆ្លងចូលឆ្នាំតាមវត្តដែលប្រារព្ធជាទូទៅ គេឃើញទំនៀមខ្លះៗក្រោយថ្ងៃចូលឆ្នាំបញ្ចប់ទៅថ្មីៗប្រារព្ធនៅតាមភូមិស្រុកនីមួយៗដែលលើកមកបង្ហាញខាងលើនេះ គឺមានលក្ខណៈពិសេសទីទៃពីគ្នាគួរឱ្យចាប់អារម្មណ៍សិក្សាស្រាវជ្រាវវែងឆ្ងាយតទៅមុខ។ ន័យជាធំនៃពិធីទាំងនោះ ភាគច្រើនពាក់ព័ន្ធនឹងជំនឿនៃការបន់ស្រន់សុំទឹកភ្លៀង សម្រាប់រដូវកសិកម្មថ្មីក្នុងខែពិសាខ ដែលរាប់ជាដើមឆ្នាំនៃការធ្វើស្រែចម្ការ៕

## ឯកសារយោង


លី សុវីរ

១៩៩៤, *បុណ្យសាងរាលុកចេតិយពូនភ្នំខ្សាច់*, ការផ្សាយរបស់អ្នកនិពន្ធ, ភ្នំពេញ

អាំង ជូលាន

២០១០-២០១១, "ឆ្លងចេត្រ", *កម្រងអត្ថបទក្នុងបណ្តាញព័ត៌មានវប្បធម៌ខ្មែរ*, លេខ៦, ទំ.៣២-៣៥, Friends of Khmer Culture, ភ្នំពេញ

ឧកញ៉ាទេពពិទូរ ក្រសេម

១៩៦, *ព្រះរាជពិធីទ្វាទសមាស*, ភាគ១, ពុទ្ធសាសនបណ្ឌិត្យ, ភ្នំពេញ


អត្ថបទដោយ៖ ហៀន សុវណ្ណមរកត